# ទំនុកដំកើង ១១៣

អ្នកនិពន្ធ រុហ្វ លេភិឡារ

**សេចក្តីណែនាំ:** នេះគឺជាទំនុកដំកើងទីមួយនៅក្នុងក្រុមទំនុកដំកើងដែលហៅថា ហាលេលអេស៊ីព្ទ (ទំនុកដំកើង ១១៣-១១៨) (សូមមើលសេចក្តីណែនាំសំរាប់ទំនុកដំកើង ១១៣-១១៨)។ ទំនុកដំកើងនេះផ្តល់ហេតុផលល្អផ្សេងៗដើម្បីឲ្យមនុស្សទាំងអស់នាំគ្នាសរសើរតម្កើងព្រះ។ ថ្វីបើទំនុកដំកើងនេះមិននិយាយអំពីការរំដោះចេញពីការគ្រប់គ្រងនៅក្នុងស្រុកអេស៊ីព្ទក៏ដោយ ក៏វានិយាយអំពីភាពអស្ចារ្យរបស់ព្រះលើគ្រប់ជាតិសាសន៍ទាំងអស់ និងអំពីសេចក្តីមេត្តាករុណារបស់ទ្រង់លើមនុស្សខ្វះខាតផងដែរ។ យើងមើលឃើញទាំងភាពអស្ចារ្យនិងសេចក្តីមេត្តាករុណារបស់ព្រះនៅពេលដែលព្រះបានសង្គ្រោះអ៊ីស្រាអែលចេញពីស្រុកអេស៊ីព្ទ។ ពួកអ៊ីស្រាអែលមានប្រពៃណីច្រៀងទំនុកដំកើងនេះនៅមុនអាហារបុណ្យរំលង។

**រចនាសម្ព័ន្ធ:** ទំនុកដំកើងនេះចាប់ផ្តើមនិងបញ្ចប់ដោយឃ្លាថា «ចូរសរសើរដល់ព្រះយេហូវ៉ា»។ ទំនុកដំកើងចែកជាបីផ្នែក ដែលផ្នែកនិមួយៗមានបីខ។

**១-៣** ឃ្លាគន្លឹះនៅក្នុងខទាំងនេះគឺ «ព្រះនាមព្រះយេហូវ៉ា» ដែលលេចឡើងក្នុងខនិមួយៗ។ ព្រះនាមរបស់ព្រះបានតំណាងឲ្យអត្តចរឹតរបស់ទ្រង់នៅពេលទ្រង់បានបើកសំដែងអង្គទ្រង់ (សូមមើលនិក្ខមនំ ៣.១៥)។ ទំនុកដំកើងបីនៅក្នុងហាលេលអេស៊ីព្ទសង្កត់ធ្ងន់លើព្រះនាមព្រះយេហូវ៉ា (១១៣, ១១៦, ១១៨)។ ទំនុកដំកើងនេះសង្កត់ធ្ងន់លើការសរសើរព្រះនាមព្រះយហូវ៉ា ទំនុកដំកើង ១១៦ សង្កត់ធ្ងន់លើការអំពាវនាវដល់ព្រះនាមព្រះយេហូវ៉ា (១១៦.៤, ១៣, ១៧) ហើយទំនុកដំកើង ១១៨ បានសរសេរបីដងថា ព្រះបំផ្លាញពួកខ្មាំងសត្រូវរបស់រាស្ត្ររបស់ទ្រង់ (ខ. ១០-១២) ហើយថ្លែងថា «សូមឲ្យព្រះអង្គ ដែលយាងមកដោយនូវព្រះនាមព្រះយេហូវ៉ា បានប្រកបដោយព្រះពរ» (ខ. ២៦)។ ដូច្នេះ ហាលេលអេស៊ីព្ទចាប់ផ្តើមដោយការហៅមនុស្សឲ្យសរសេរតម្កើងដល់ព្រះនាមរបស់ព្រះអម្ចាស់ (១១៣.១-៣) ហើយបញ្ចប់ដោយការបញ្ចូលសេចក្តីថ្លែងមួយថា «សូមព្រះអង្គ ដែលយាងមកដោយព្រះនាមព្រះយេហូវ៉ា បានប្រកបដោយព្រះពរ»។

**១** «អ្នកបំរើនៃព្រះយេហូវ៉ា» គឺជារបៀបបរិយាយអំពីរាស្ត្ររបស់ព្រះ (រាស្ត្រដែលទ្រង់បានប្រោសលោះ)។ យើងគឺជាអ្នកបំរើរបស់ទ្រង់អស់កល្បជានិច្ច (វិវរណៈ ២២.៣)។

**២** មនុស្សគួរតែសរសើរតម្កើងព្រះគ្រប់ពេលវេលា។

**៣** គឺជារូបភាពដែលបង្ហាញថា មនុស្សគួរតែសរសើរតម្កើងព្រះក្នុងគ្រប់ទីកន្លែងទាំងអស់។

**៤-៦** ខទាំងនេះផ្តល់ហេតុផលផ្សេងៗដែលយើងគួរតែសរសើរតម្កើងដល់ព្រះ។ តើមានហេតុផលអ្វីខ្លះនៅទីនេះ?

ខទាំងនេះបរិយាយអំពីភាពឧត្តុង្គឧត្តមរបស់ព្រះ ដែលទ្រង់អស្ចារ្យយ៉ាងខ្លាំងជាងពិភពលោកដែលទ្រង់បានបង្កើតមកទៅទៀត។ សំនួរនៅក្នុងខ. ៥ គឺជាសំនួរអស្ចារ្យមួយក្នុងចំណោមសំនួរទាំងអស់នៅក្នុងព្រះគម្ពីរ (សូមមើលផងដែរ និក្ខមនំ ១៥.១១; ចោទិយកថា ៣.២៤; ទំនុកដំកើង ៣៥.១០, ៨៩.៦, ៨; អេសាយ ៤០.១២-៤១.៤)។ ឈ្មោះរបស់ពួកមនុស្សនិងពួកទេវតា (មីកាយ៉ា «តើអ្នកណាដូចជាព្រះយ៉ាវេ?» មីកែល «តើអ្នកណាដូចជាព្រះជាម្ចាស់?») បង្ហាញអំពីផ្ទៃរឿងនេះនៅក្នុងព្រះគម្ពីរ។ ចំលើយច្បាស់លាស់គឺ គ្មានអ្នកណាដូចជាទ្រង់សោះ គឺទ្រង់ពិសេសដាច់ដោយឡែកតែមួយអង្គទ្រង់។

**៧-៩** ផ្តល់ហេតុផលបន្ថែមទៀតដែលយើងគួរតែសរសើរតម្កើងព្រះ។ តើមានហេតុផលអ្វីខ្លះនៅទីនេះ?

ខ. ៤-៦ បរិយាយអំពីភាពឧត្តុង្គឧត្តមរបស់ព្រះ ខ. ៧-៩ បរិយាយអំពីសកម្មភាពរបស់ព្រះ។ ទ្រង់ផ្លាស់ប្តូរស្ថានភាពរបស់មនុស្សកំសត់ទុគ៌តដោយអំណាចនិងសេចក្តីមេត្តាករុណារបស់ទ្រង់។ សកម្មភាពទាំងនេះគឺជាផ្នែកនៃសិរីល្អរបស់ទ្រង់។

មានទំនាក់ទំនងមួយរវាងខ. ៤-៥ និង ៧-៨។ ពាក្យឫសភាសាហេព្រើនៅក្នុងខ. ៤ ដែលបានបកប្រែថា ស្ថិតនៅទីខ្ពស់ *លើ* គឺ៊ោ។ ពាក្យហេព្រើនេះមានម្តងទៀតនៅក្នុងខ. ៧ ដែលបានបកប្រែថា *លើក*។ ព្រះគង់នៅទីខ្ពស់ ហើយទ្រង់លើកមនុស្សកំសត់ទុគ៌តឡើង។ ខ. ៥ និង៨ មានពាក្យហេព្រើដូចគ្នាសំរាប់ការអង្គុយ (បានបកប្រែថា *គង់* នៅក្នុងខ. ៥)។ ព្រះគង់នៅទីខ្ពស់ ហើយទ្រង់លើកមនុស្សក្រីក្រឲ្យអង្គុយលើកន្លែងខ្ពស់ជាមួយពួកអ្នកធំ។ ការដែលត្រូវបានព្រះលើកឡើងពីស្ថានភាពកំសត់ទុគ៌តឲ្យអង្គុយជាមួយពួកអ្នកធំគឺជារូបភាពមួយដែលប៉ុលប្រើដើម្បីបរិយាយអំពីសេចក្តីសង្គ្រោះរបស់យើងតាមរយៈព្រះយេស៊ូវ (អេភេសូរ ២.១-៦)។

*៩*. និយាយអំពីការដែលព្រះប្រទានឲ្យពួកស្ត្រីអារមានកូន។ ហាណាគឺជាស្ត្រីអារដែលព្រះបានប្រទានឲ្យមានកូន។ ដូច្នេះ ហាណាបានច្រៀងបទចម្រៀងសរសើរតម្កើងដែលស្រដៀងនឹងទំនុកដំកើងនេះ (សូមមើល១សាំយ៉ូអែល ២.១.១-១០)។ បទចម្រៀងរបស់ម៉ារាអំពីការមានទារកព្រះយេស៊ូវនៅក្នុងផ្ទៃក៏មានផ្ទៃរឿងស្រដៀងគ្នានេះផងដែរ (លូកា ១.៤៦-៥៥)។

**ការអនុវត្តៈ** ទំនុកដំកើងនេះមិនគ្រាន់តែសរសើរតម្កើងព្រះនោះទេ ប៉ុន្តែវាក៏ហៅឲ្យយើងសរសើរតម្កើងព្រះផងដែរ។ យើងមិនគួរគ្រាន់តែសរសើរតម្កើងព្រះនោះទេ ប៉ុន្តែយើងក៏គួរតែហៅឲ្យអ្នកដទៃសរសើរតម្កើងទ្រង់ ពីព្រោះទ្រង់មានភាពឧត្តុង្គឧត្តមនិងសេចក្តីមេត្តាករុណាផងដែរ។ ការនេះបង្ហាញយើងឲ្យឃើញថា ព្រះអង្គខុសពីពួកព្រះដទៃទៀតដែលនៅក្នុងគតិលោកផ្សេងៗទៀត។ នៅក្នុងប្រវត្តិសាស្ត្រមានមនុស្សខ្លះដែលមានវប្បធម៌ផ្សេងៗទៀតជឿថា ពួកព្រះដែលមានភាពឧត្តុង្គឧត្តមមិនបានចាប់អារម្មណ៍លើមនុស្សនោះទេ។ ទំនុកដំកើងនេះបង្រៀនយើងយ៉ាងច្បាស់លាស់ថា ព្រះមានភាពឧត្តុង្គឧត្តមហើយក៏មានសេចក្តីមេត្តាករុណាមកលើមនុស្សតូចទាបផងដែរ។ ការរួមបញ្ចូលនៃអំណាចដ៏អស្ចារ្យលើជាតិសាសន៍ទាំងអស់និងសេចក្តីមេត្តាករុណាលើមនុស្សម្នាក់ៗគឺជាមូលហេតុដែលនាំឲ្យគ្មានអ្នកណាដូចជាព្រះសោះ។ យើងមើលឃើញការនេះយ៉ាងច្បាស់បំផុតនៅក្នុងជីវិតនិងព័ន្ធកិច្ចរបស់ព្រះយេស៊ូវ។

ដូច្នេះ ការសំឡឹងទៅឯព្រះយេស៊ូវលើកទឹកចិត្តឲ្យយើងសរសើរតម្កើងព្រះ។ ជនជាតិអ៊ីស្រាអែលអាចងាកទៅមើលការដែលព្រះបានសង្គ្រោះពួកគេចេញពីអេស៊ីព្ទ ដើម្បីសរសើរតម្កើងព្រះសំរាប់ភាពឧត្តុង្គឧត្តមនិងសេចក្តីមេត្តាករុណារបស់ទ្រង់។

ពួកគ្រីស្ទបរិស័ទអាចងាកមើលលើការរំដោះចេញពីការគ្រប់គ្រងពីស្រុកអេស៊ីព្ទ ហើយលើសពីនោះទៅទៀតអាចងាកមើលលើជីវិតការសុគត ការរស់ឡើងវិញ និងការយាងត្រឡប់ទៅស្ថានសួគ៌វិញរបស់ព្រះយេស៊ូវ ដើម្បីមើលឃើញភាពឧត្តុង្គឧត្តមនិងសេចក្តីមេត្តាករុណារបស់ទ្រង់។ យើងគួរតែប្រកាសអំពីជីវិត ព័ន្ធកិច្ច និងការសុគតរបស់ព្រះយេស៊ូវទៅកាន់មនុស្ស ដើម្បីឲ្យពួកគេអាចមើលឃើញការបើកសំដែងអំពីភាពឧត្តុង្គឧត្តម សេចក្តីមេត្តាករុណា និងសិរីល្អរបស់ព្រះ (យ៉ូហាន ១.១៤)។ លើសពីនេះទៅទៀត យើងគួរតែដើរតាមគំរូសេចក្តីស្រលាញ់និងសេចក្តីមេត្តាករុណារបស់ព្រះយេស៊ូវ ដើម្បីយើងអាចបញ្ចេញអត្តចរឹតរបស់ព្រះ ដែលនឹងលើកទឹកចិត្តឲ្យអ្នកដទៃសរសើរតម្កើងដល់ព្រះផងដែរ (ម៉ាថាយ ៥.១៦)។ ទំនុកដំកើងនេះនិយាយថា យើងគួរតែសរសើរតម្កើងព្រះអស់កល្បជានិច្ច ដូច្នេះ យើងមានអំណរដែលនៅក្នុងការបង្កបង្កើតថ្មី ពួកអ្នកបំរើរបស់ព្រះទាំងអស់នឹងកំពុងសរសើរតម្កើងដល់ព្រះនិងកូនចៀមអស់កល្បជានិច្ច។

## Bibliography


*Biblia Hebraica Stuttgartensia: With Westminster Hebrew Morphology.* 1995. Stuttgart; Glenside PA: German Bible Society; Westminster Seminary.

Carson, D. A., France, R. T., Motyer, J. A., & Wenham, G. J. (Eds.). (1994). *New Bible Commentary: 21st century edition* (4th ed.). Leicester, England; Downers Grove, IL: Inter-Varsity Press.

Garrett, D. A. (1998). *The Poetic and Wisdom Books*. (D. S. Dockery, Ed.) *Holman concise Bible commentary*. Nashville, TN: Broadman & Holman Publishers.

Calvin, J., & Anderson, J. (2010). *Commentary on the Book of Psalms* (Vol. 4, pp. 330–335). Bellingham, WA: Logos Bible Software.

Jamieson, R., Fausset, A. R., & Brown, D. (1997). *Commentary Critical and Explanatory on the Whole Bible*. Oak Harbor, WA: Logos Research Systems, Inc.

Kidner, D. (1975). *Psalms 73–150: An Introduction and Commentary* (Vol. 16, pp. 435–437). Nottingham, England: Inter-Varsity Press.

VanGemeren, W. A. (1991). *Psalms*. (F. E. Gaebelein, Ed.)*The Expositor's Bible Commentary: Psalms, Proverbs, Ecclesiastes, Song of Songs*. Grand Rapids, MI: Zondervan Publishing House.